## ព័ត៌មានសំរាប់ជនរងគ្រោះ

ក្រមនៃក្រឹត្យសិទ្ធិរបស់ជនរងគ្រោះ រដ្ឋកាលីហ្វ័រនីញ៉ា – ច្បាប់របស់ Marsy – ផ្តល់ឲ្យអ្នក នូវសិទ្ធិស្របច្បាប់សំខាន់ៗទាំងនេះ៖

### ទទួលប្រាក់ សំរាប់ការខាតបង់របស់អ្នក

ដាក់ពាក្យសុំប្រាក់ ដើម្បីរ៉ាប់រងការខាតបង់ទ្រព្យសម្បត្តិរបស់អ្នក, ចំណាយថ្លៃពេទ្យ, បាត់បង់ថ្លៃឈ្នួល, និងការខាតបង់ផ្សេងៗទៀត។

### ថ្លែងអំពីឧក្រិដ្ឋកម្ម បានប៉ះទង្គិចដល់អ្នកជាយ៉ាងណា

ប្រាប់តុលាការអំពីឧក្រិដ្ឋកម្ម បានប៉ះទង្គិចដល់ជីវិតរបស់អ្នកជាយ៉ាងណា មុនពេលជនចុងចោទ ត្រូវបានកាត់ទោស។

### ទទួលព័ត៌មាន អំពីករណីឧក្រិដ្ឋកម្ម

ស្នើសុំរដ្ឋអាជ្ញា នូវព័ត៌មានខ្លះអំពីករណី។

### ទទួលបទបញ្ជាពីតុលាការ

តុលាការ អាចដាក់បទបញ្ជាដែលអាចនឹងជួយអ្នកបាន ដូចជា **បទបញ្ជាការពារ** ដើម្បីរក្សាអ្នកចុងចោទ ឲ្យនៅឆ្ងាយពីអ្នក **ឬបទបញ្ជាឲ្យបង់ថ្លៃឈ្នួលមេធាវី** បើសិនអ្នកបានជួលមេធាវីឲ្យជួយជាមួយនឹងករណីរបស់អ្នក។

តុលាការ ក៏អាចបញ្ជាឲ្យអ្នកចុងចោទ បង់ប្រាក់ឲ្យអ្នកចំនួន $25,000 ឬច្រើនជាង សំរាប់ការប្រព្រឹត្តិល្មើសសិទ្ធិពលរដ្ឋរបស់អ្នក។ (ពិគ្រោះជាមួយមេធាវី អំពីសិទ្ធិរបស់អ្នកនៅក្រោមក្រឹត្យ Ralph និងក្រឹត្យ Bane)។

## ទីកន្លែងដើម្បីរកជំនួយ

- ការិយាល័យរបស់អគ្គមេធាវី រដ្ឋកាលីហ្វ័រនីញ៉ា ផ្នែកសេវាជនរងគ្រោះ
  (877) 433-9069
  TTY: (800) 735-2929
  www.oag.ca.gov/victimservices
- ក្រសួងយុត្តិធម៌ការងារ និងលំនៅដ្ឋាន រដ្ឋកាលីហ្វ័រនីញ៉ា
  (800) 884-1684
  TTY: (800) 700-2320
  www.dfeh.ca.gov
- គណៈសងប្រាក់ឲ្យជនរងគ្រោះ រដ្ឋកាលីហ្វ័រនីញ៉ា
  (800) 777-9229
  www.vcgcb.ca.gov
  - រកការិយាល័យរបស់មេធាវីមណ្ឌល ក្នុងមូលដ្ឋានរបស់អ្នក, មជ្ឈមណ្ឌលជនរងគ្រោះ/សាក្សី
    www.vcgcb.ca.gov/victims/localhelp.aspx
- ក្រសួងយុត្តិធម៌សហរដ្ឋ, សេវាទំនាក់ទំនងសហគមន៍
  (202) 305-2935
  www.justice.gov/crs

សំរាប់ព័ត៌មានបន្ថែម ឬជំនួយ ជាមួយនឹងសំណួរ ឬកង្វល់ ទាក់ទង៖

**ការិយាល័យរបស់អគ្គមេធាវី រដ្ឋកាលីហ្វ័រនីញ៉ា**
**ផ្នែកសេវាជនរងគ្រោះ**
P.O. Box 944255
Sacramento, CA 94244-2550
(877) 433-9069
www.oag.ca.gov/victimservices

Funded by the U.S. Dept. of Justice,
Victims of Crime Act, 2017-VA-GX-0084

B13–9119 – 10/2018 Cambodian

# ឧក្រិដ្ឋកម្មសំអប



## អ្វីៗដែលអ្នកត្រូវដឹង ដើម្បីការពារខ្លួនអ្នក និងអ្នកផ្សេងៗ

ការិយាល័យរបស់អគ្គមេធាវី រដ្ឋកាលីហ្វ័រនីញ៉ា
ផ្នែកសេវាជនរងគ្រោះ

*នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា អ្នកអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មសំអប់ បើសិនគេបានប៉ងធ្វើមកលើអ្នក ពីព្រោះតែ៖*

» *ជាតិសាសន៍ ឬជាតិពន្ធ,*
» *ដើមកំណើត, សាសនា,*
» *ភិនភេទ, លក្ខណៈសេពសន្ថវៈ,*
» *ពិការរូបកាយ ឬផ្លូវចិត្ត, ឬ*
» *ការសេពគប់របស់អ្នក ជាមួយនឹងមនុស្ស ឬក្រុមមួយ ដោយមានបុគ្គលិកលក្ខណៈ "ពិតប្រាកដ" ឬ "បានយល់" ទាំងនេះមួយ ឬច្រើនជាង។*

## តើឧក្រឹដ្ឋកម្មសំអប់ ឬឧប្បត្តិហេតុសំអប់?

វាជាសារៈសំខាន់ ដើម្បីស្គាល់ភាពខុសគ្នា រវាង*ឧក្រឹដ្ឋកម្មសំអប់* និង*ឧប្បត្តិហេតុសំអប់*។

**ឧប្បត្តិហេតុសំអប់** គឺជាការប្រព្រឹត្តិ ឬជាកិរិយា ដែលបានញ៉ាំងចិត្ត ដោយសារការស្អប់ ប៉ុន្តែត្រូវបានការពារដោយវិសោធនកម្មដំបូង នៃសិទ្ធិចំពោះសេរីភាពនៃការបញ្ចេញវាចា។

ឧទាហរណ៍នៃឧប្បត្តិហេតុសំអប់ រួមមានទូវ៖

- ការមាក់ងាយឈ្មោះ,
- ការជេរប្រមាថ,
- ការចែកចាយសំភារៈសំអប់ នៅក្នុងកន្លែងសាធារណៈ, និង
- ការបង្ហាញសំភារៈសំអប់ នៅលើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នក។

រដ្ឋធម្មនុញ្ញសហរដ្ឋ អនុញ្ញាតសំដីសំអប់ ដរាបណាវាមិនជ្រៀតជ្រែកជាមួយនឹងកិច្ចការ នៃសិទ្ធិពលរដ្ឋផ្សេងៗទៀត។ បើសិនឧប្បត្តិហេតុសំអប់ ចាប់ផ្តើមគំរាមកំហែងដល់មនុស្ស ឬទ្រព្យសម្បត្តិ វាអាចនឹងក្លាយជា **ឧក្រឹដ្ឋកម្មសំអប់**។

**ឧក្រឹដ្ឋកម្មសំអប់** គឺជាបទឧក្រឹដ្ឋមួយ ប្រឆាំងនឹងមនុស្សម្នាក់ ឬក្រុមមួយ ឬទ្រព្យសម្បត្តិ ដែលបាននាំចិត្តឲ្យធ្វើទៅលើជនរងគ្រោះពិត ឬក្រុមសង្គមដែលការពារ ដោយបានយល់។ ច្បាប់ការពារប្រឆាំងនឹងថ្នាក់ជាច្រើន នៃឧក្រឹដ្ឋកម្មសំអប់។

## តូវធ្វើអ្វីខ្លះ បើសិនអ្នកធ្វើសាក្សីឧក្រឹដ្ឋកម្មសំអប់

រាយការណ៍បទឧក្រឹដ្ឋ ទៅនគរបាល ឬក្រសួងតម្រួត ក្នុងមូលដ្ឋានរបស់អ្នក។ បើសិនឧក្រឹដ្ឋកម្មសំអប់ មិនបានរាយការណ៍ទេ ឧក្រឹដ្ឋកម្មសំអប់អាចនឹងមានបន្តទៅទៀត។

## របៀបដើម្បីសំគាល់ ឧក្រឹដ្ឋកម្មសំអប់

នេះគឺជាសញ្ញានៃឧក្រឹដ្ឋកម្មសំអប់ ដែលអាចមាន៖

- ឧក្រិដ្ឋជន ជ្រើសរើសជនរងគ្រោះ ឬទ្រព្យសម្បត្តិ ពីព្រោះគេនៅក្នុងក្រុមមួយដែលបានការពារ ដូចជាសាសនា ឬភិនភេទខ្លះ។
- ឧក្រិដ្ឋជន បានបញ្ចេញយោបល់ ជាលាយល័ក្ខណ៍អក្សរ ឬវាចា ដែលបង្ហាញការប្រកាន់ពូជសាសន៍។
- ឧក្រិដ្ឋកម្មបានកើតឡើង នៅកាលបរិច្ឆេទដែលជាសំខាន់សំរាប់ក្រុមដែលបានការពារ របស់ជនរងគ្រោះ។
- វាមានសកម្មភាពសំអប់ជាច្រើន ដែលបានរៀបចំនៅក្នុងតំបន់។

> *"នៅពេលជនណាម្នាក់ ប្រព្រឹត្តឧក្រឹដ្ឋកម្មដែលបាននាំចិត្តឲ្យធ្វើដោយការស្អប់ វាគឺមិនមែនគ្រាន់តែជាការវាយប្រហារ ទៅលើមនុស្សគ្មានទោសឡើយ ប៉ុន្តែក៏វាយប្រហារទៅលើរដ្ឋទាំងមូលដែរ"។*
>
> *Xavier Becerra*
> *អគ្គមេធាវី រដ្ឋកាលីហ្វ័រនីញ៉ា*

## បើសិនអ្នកជាជនរងគ្រោះ នៃឧក្រឹដ្ឋកម្មសំអប់ អ្នកគួរតែ៖

- ទាក់ទងនគរបាល ឬតម្រួត ក្នុងមូលដ្ឋានរបស់អ្នក ភ្លាមៗ!
- ទទួលការព្យាបាលរោគ (បើសិនអ្នកត្រូវការវា)។
- កត់ពាក្យពេចន៍ពិតៗ ដែលបាននិយាយ។
- ធ្វើកំណត់សំគាល់ អំពីការពិតផ្សេងៗអ្វីមួយ ប្រយោជន៍កុំឲ្យអ្នកភ្លេចវា។
- សន្សំទុកភស្តុតាងទាំងអស់ (ដូចជា រូបគំនូរ, សំបកពងមាន់, ការសរសេរនៅលើរថយន្តរបស់ជនរងគ្រោះ)។ បើសិនមានសុវត្ថិភាព រង់ចាំរហូតដល់នគរបាលច្បាប់មកដល់ និងថតរូប។
- យកឈ្មោះ, អាសយដ្ឋាន, លេខទូរស័ព្ទ, និងអ៊ីមេល របស់ជនរងគ្រោះ និងសាក្សីផ្សេងៗទៀត។
- ព្យាយាមឲ្យបានការពណ៌នា ពីកសិណសាក្សីណាម្នាក់ អំពីឧក្រិដ្ឋជន ឬរថយន្ត។
- ទូរស័ព្ទទៅអង្គការសហគមន៍ នៅក្នុងតំបន់របស់អ្នក ដែលឆ្លើយតបចំពោះឧក្រឹដ្ឋកម្មសំអប់។

## អ្វីៗដែលអ្នក និងសហគមន៍របស់អ្នក អាចធ្វើ

- និយាយបញ្ចេញមតិ ប្រឆាំងនឹងការស្អប់គ្នា និងការមិនអត់ឱន។
- ឲ្យមានសហគមន៍រួបរួមព្រួតដៃគ្នា ដើម្បីគាំទ្រជនរងគ្រោះ។
- ផ្តល់ជូនការគាំទ្រ និងជួយដល់ជនរងគ្រោះ។
- ស្នើមន្ត្រីសាធារណៈ ឲ្យនិយាយបញ្ចេញមតិ ប្រឆាំងនឹងឧក្រឹដ្ឋកម្មសំអប់។
- ស្ថាបនាបណ្តាញឧក្រឹដ្ឋកម្មសំអប់ ដែលមានបញ្ចូលទូវនគរបាលច្បាប់ រដ្ឋាភិបាលមូលដ្ឋាន សាលារៀន អង្គការសាសនា និងអង្គការសហគមន៍។ សូមឲ្យគេតបឆ្លើយចំពោះឧក្រឹដ្ឋកម្មសំអប់ភ្លាមៗ នៅពេលវាកើតឡើង និងផ្សព្វផ្សាយវិធីការពារ និងការដឹង។